**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
លេខ ៧៥៨ ប្រ.ក

ភ្នំពេញ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និង ប្រគល់កិច្ចសន្យាលទ្ធកម្ម (PEAC)

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦ ០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រិត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រិត្យលេខ៦០អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ៣១៩ កហវ.ប្រក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៥ និងសេចក្តីណែនាំលេខ០០៦ សណន.សហវ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និងបទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្ម សាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យាលទ្ធកម្មហៅកាត់ថាគណៈកម្មាធិការ (PEAC) នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចតទៅ:

| | | | |
|---|---|---|---|
| ១- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ | | | ជាប្រធាន |
| ២- ឯកឧត្តម | ស៊ឹម សារ៉ាក់ | | ជាអនុប្រធាន |
| ៣- លោក | ខាស សារុន | | សមាជិក |
| ៤- លោក | អួង ចន | | សមាជិក |
| ៥- លោកស្រី | លន់ សាឌី | | សមាជិក |
| ៦- លោកស្រី | ទេព សនណារីច | | សមាជិក |
| ៧- លោក | ចំនួ ចណ្ណា | ប្រធាន PU | សមាជិក-លេខាធិការ |

<u>**ប្រការ២**</u> : គណៈកម្មាធិការ PEAC មានភារកិច្ចដូចតទៅ :-

- កំណត់បុរេលក្ខណៈសម្បត្តិ នៃការដេញថ្លៃទំនិញ-ការសាងសង់-សេវា
- វាយតំលៃលើសំណើដេញថ្លៃ-ពិគ្រោះថ្លៃ
- ផ្តល់អនុសាសន៍ថ្វាយ-ជូនប្រធានស្ថាប័ន ពិនិត្យសំរេច និងប្រគល់កិច្ចសន្យា
- មានសិទ្ធិកោះអញ្ជើញបណ្តាផ្នែកជំនាញ ក្រោមឱវាទដែលពាក់ព័ន្ធ និងចម្លងការលទ្ធកម្មមកបំភ្លឺ និងផ្តល់យោបល់ពីការងារបច្ចេកទេសក្នុងករណីចាំបាច់ ។

<u>**ប្រការ៣**</u> : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ បណ្តាអង្គភាពពាក់ព័ន្ធ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្ត-ក្រុង អ្នកអង្គម្ចាស់ ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះ ដូចក្នុងប្រការ១ មានភារកិច្ចត្រូវអនុវត្តប្រកាសនេះ ។

<u>**ប្រការ៤**</u> : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ហើយរាល់សេចក្តីសំរេចដែលមានពីមុន និងផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>**ចម្លងជូន**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

  *(ដើម្បីជូនជ្រាប)*
- ដូចប្រការ១ និង៣
- ឯកសារ-កាលប្បវត្តិ